ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តតាកែវ**
សំណុំរឿងព្រហ្មទណ្ឌលេខ ៤២១
ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៣
សំណុំរឿងជំនុំជម្រះលេខ ៨៨៥
ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣
សាលក្រមព្រហ្មទណ្ឌលេខ ០៩ "ថ"
ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៤

## នាមនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តតាកែវ បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤ វេលាម៉ោង ៨:៣០ នាទីព្រឹក ដោយមានសមាសភាព៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តតាកែវ

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤២១ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

ក.នាមត្រកូល [redacted] នាមខ្លួន មិថុនា ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរជាងដែក ទីកន្លែងកំណើត ភូមិ[redacted] ខេត្តតាកែវ និងទីលំនៅមុនពេលឃាត់ខ្លួនភូមិ[redacted] ខេត្តតាកែវ ឪពុកឈ្មោះ [redacted] គឿន (រ) ម្តាយឈ្មោះ [redacted] សំបូរ (រ) នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ (ក្នុងឃុំ)

(ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៣៤០/២៣ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣ )

ខ.នាមត្រកូល [redacted] នាមខ្លួន បញ្ញា ភេទ ប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរកម្មករសំណង់ ទីកន្លែងកំណើត ភូមិ[redacted] ខេត្តតាកែវ និងទីលំនៅមុនពេលឃាត់ខ្លួន ភូមិ[redacted] ខេត្តតាកែវ ឪពុកឈ្មោះ [redacted] សៀងលី (រ) ម្តាយឈ្មោះ [redacted] ណារី (រ) នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ (ក្នុងឃុំ)

(ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៣៤១/២៣ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣)

គ.នាមត្រកូល [redacted] នាមខ្លួន ថយ ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរជាងដែក ទីកន្លែងកំណើត ភូមិ[redacted] ខេត្តតាកែវ និងទីលំនៅមុនពេលឃាត់ខ្លួនភូមិ[redacted] ខេត្តតាកែវ ឪពុកឈ្មោះ [redacted] ធី (ស) ម្តាយឈ្មោះ [redacted] ផល (រ) ប្រពន្ធឈ្មោះ [redacted] ស្រីល័ក្ខ (លែងលះ) មានកូន ០២នាក់ ជានីតិជន ទោសពីមុនគ្មាន ។ (ក្នុងឃុំ)



Scanned with CamScanner

(ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣៣៩/២៣ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣)

ជាប់ចោទពីបទៈ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិអង្គត្រាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ឃ.នាមត្រកូល [redacted] នាមខ្លួន **អ៊ារ ហៅ អៀវ** ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករសំណង់ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើត ភូមិ[redacted] ខេត្តតាកែវ និងទីលំនៅមុនពេលឃាត់ខ្លួនភូមិ[redacted] ខេត្តតាកែវ ឪពុកឈ្មោះ (មិនស្គាល់) ម្តាយឈ្មោះ[redacted]គីមហ៊ាន (រ) ប្រពន្ធឈ្មោះ [redacted] ស្រីតូច (លែងលះ) មានកូនចំនួន ០១នាក់ ជានីតិជន ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារចំនួន ០២ ឆ្នាំ ពីបទៈ គ្រឿងញៀន ។ (ក្នុងឃុំ)

ជាប់ចោទពីបទៈ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិអង្គត្រាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **មិថុនា** ,ឈ្មោះ [redacted] **បញ្ញា** ,ឈ្មោះ [redacted] **ថយ** និងឈ្មោះ [redacted] **អ៊ារ ហៅ អៀវ** ។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **អ៊ារ ហៅ អៀវ** ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ៧៤៥ ដ.ស.ព/២៣ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តតាកែវ ។

-**បានឃើញ** ដីកាដំណោះស្រាយលេខ ៦៥៧/២៣ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តតាកែវ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង ១៦ និង ០០នាទី កម្លាំងការិយាល័យគ្រឿងញៀន បានចុះបង្ក្រាបករណី **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** នៅចំណុចភូមិអង្គត្រាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ ដោយឃាត់បានជនជាប់ចោទចំនួន ០៣នាក់ ទី១ ឈ្មោះ [redacted] **ថយ** ភេទប្រុស អាយុ៣៨ឆ្នាំ ទី២ ឈ្មោះ [redacted] **បញ្ញា** ភេទប្រុស អាយុ ២០ឆ្នាំ និងទី៣ ឈ្មោះ [redacted] **មិថុនា** ភេទប្រុស អាយុ ២១ឆ្នាំ ។ ដកហូតបានសម្ភារៈដូចជា សារធាតុញៀនប្រភេទមេតំហ្វេតាមីន (ICE) ចំនួន ០៣កញ្ចប់តូច ទម្ងន់ ២៥.៧៦ ក្រាម កាំភ្លើងកែច្នៃចំនួន ០១ដើម, ដាវចំនួន ០១ដើម និងឧបករណ៍ប្រើប្រាស់មួយចំនួន ។ តាមចម្លើយឈ្មោះ [redacted] **មិថុនា** បានឆ្លើយថាថ្នាំញៀនដែលសមត្ថកិច្ចដកហូតគឺជារបស់ឈ្មោះ [redacted] **អ៊ារ ហៅ អៀវ** ភេទប្រុស អាយុ ៣១ឆ្នាំ ។ បន្ទាប់មកសមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនទៅអយ្យការអមសាលាដំបូងខេត្តតាកែវ ដើម្បីចាត់ការតាមនីតិវិធី ។



Scanned with CamScanner

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] មិថុនា ឆ្លើយថា: នៅថ្ងៃកើតហេតុ ឈ្មោះ [redacted] **អ៊ាវ** ខលហៅខ្ញុំយកថ្នាំញៀនឱ្យគេនៅវត្តនាគត្រាច ។ ប៉ុន្តែត្រូវសមត្ថកិច្ចឃាត់ខ្លួននៅតាមផ្លូវ ។ កន្លងមក ខ្ញុំធ្លាប់យកថ្នាំញៀនឱ្យឈ្មោះ **អ៊ាវ** ចំនួន ០១ លើក ហើយខ្ញុំធ្លាប់ប្រើប្រាស់ថ្នាំញៀនគាត់ ចំនួន ០១ ដង ។ ខ្ញុំស្គាល់ឈ្មោះ **អ៊ាវ** តាមរយៈឈ្មោះ **ទីន** ។ បើខ្ញុំជួយយកថ្នាំញៀន គេឱ្យលុយចាយខ្លះ ។ ពេលសមត្ថកិច្ចឃាត់ខ្លួន បានតេស្តទឹកនោម និងដកហូតថ្នាំញៀននៅជិតវត្ត ។ នៅថ្ងៃសមត្ថកិច្ចឃាត់ខ្លួនបានចូលឆែកឆេរផ្ទះរបស់ឈ្មោះ **អ៊ាវ** ប៉ុន្តែមិនមានថ្នាំញៀននោះទេ ។ ឈ្មោះ **អ៊ាវ** ដែលប្រើខ្ញុំឱ្យយកថ្នាំញៀនឱ្យគេ គឺជាឈ្មោះ [redacted] **អ៊ាវ** ដែលនៅចំពោះមុខខ្ញុំនេះហើយ ។ ចំពោះថ្នាំញៀនដែលសមត្ថកិច្ចដកហូត ខ្ញុំយកពីផ្ទះឈ្មោះ **អ៊ាវ** តម្លៃ ១ លាន ៨០ ម៉ឺនរៀល ។ ពេលសមត្ថកិច្ចឃាត់ខ្លួន បានតេស្តទឹកនោម ។

-ជនជាប់ចោទឈ្មោះ [redacted] **អ៊ាវ** ឆ្លើយថា: នៅថ្ងៃកើតហេតុ ខ្ញុំនៅត្រពាំងធំទៅធ្វើការងារ ។ ឈ្មោះ [redacted] **ថយ** ,ឈ្មោះ [redacted] **មិថុនា** ,ឈ្មោះ [redacted] បញ្ញា គឺស្នាក់នៅផ្ទះរបស់ខ្ញុំ ។ ខ្ញុំស្នាក់នៅផ្ទះរបស់ខ្ញុំរហូតមិនបានចេញទៅណានោះទេ ទើបតែនៅថ្ងៃទី២៧ខែមករា ឆ្នាំ២០២៤ សមត្ថកិច្ចឃាត់ខ្លួន ។ ខ្ញុំសូមបដិសេធ ខ្ញុំមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ។ ចំពោះថ្នាំញៀនដែលសមត្ថកិច្ចដកហូត ខ្ញុំមិនដឹងថា ជារបស់អ្នកណានោះទេ ។ បន្ទាប់ពីសមត្ថកិច្ចឃាត់ខ្លួន ឈ្មោះ [redacted] **មិថុនា** ,ឈ្មោះ [redacted] **បញ្ញា** និងឈ្មោះ [redacted] **ថយ** ពេលល្ងាចទើបខ្ញុំត្រឡប់មកផ្ទះវិញ ។ ខ្ញុំមិនបានរត់គេចពីសមត្ថកិច្ចនោះទេ ពីព្រោះខ្ញុំមិនជាប់ពាក់ព័ន្ធឡើយ ។ នៅថ្ងៃសមត្ថកិច្ចឃាត់ខ្លួន ខ្ញុំមិនដឹងថាដកហូតបានអ្វីខ្លះនោះទេ ។ ខ្ញុំសូមបដិសេធ ខ្ញុំមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ។

-ជនជាប់ចោទឈ្មោះ [redacted] **ថយ** ឆ្លើយថា: កន្លងមក ខ្ញុំទិញថ្នាំញៀនពីឈ្មោះ បញ្ញា ។ ខ្ញុំមិនធ្លាប់ទិញថ្នាំញៀនពីឈ្មោះ [redacted] **ថយ** នោះទេ ។ ខ្ញុំមិនបានទិញថ្នាំញៀនពីឈ្មោះ **អ៊ាវ** នោះទេ ។ កន្លងមក ឈ្មោះ **មិថុនា** មិនធ្លាប់ប្រើខ្ញុំឱ្យយកថ្នាំញៀនឱ្យគេនោះទេ ហើយខ្ញុំក៏មិនដឹងថា ឈ្មោះ **មិថុនា** យកថ្នាំញៀនឱ្យអ្នកណាខ្លះនោះដែរ ។ ខ្ញុំស្គាល់ឈ្មោះ [redacted] **អ៊ាវ** តាមរយៈទៅធ្វើផ្ទះឱ្យគាត់ ។ ខ្ញុំមិនដឹងថា ឈ្មោះ [redacted] **អ៊ាវ** ជាអ្នកលក់ថ្នាំញៀន ឬអត់នោះទេ ហើយខ្ញុំក៏មិនធ្លាប់ប្រើប្រាស់ថ្នាំញៀនជាមួយគាត់ដែរ ។

-ជនជាប់ចោទឈ្មោះ [redacted] បញ្ញា ឆ្លើយថា: នៅថ្ងៃសមត្ថកិច្ចឃាត់ខ្លួន ខ្ញុំកំពុងចាក់សាបនៅផ្ទះរបស់ឈ្មោះ **អ៊ាវ** ។ ខ្ញុំមិនបានទិញថ្នាំញៀនពីឈ្មោះ [redacted] **អ៊ាវ** ហើយក៏មិនដឹងថា គាត់លក់ថ្នាំញៀន ឬអត់នោះទេ ។ ខ្ញុំស្គាល់ឈ្មោះ [redacted] **ថយ** ,ឈ្មោះ [redacted] **មិថុនា** ,ឈ្មោះ [redacted] **អ៊ាវ** ។

**តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថ្លែងសុំថា**

ក្រោយពីការពិភាក្សាដេញដោលក្នុងសវនាការ ,ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទរួចមក ឃើញថា ជនជាប់ចោទឈ្មោះ [redacted] **មិថុនា** បានឆ្លើយសារភាពថា បានជួញដូរ និងប្រើប្រាស់ថ្នាំញៀនដោយខុសច្បាប់ប្រាកដមែន។ ចំណែកជនជាប់ចោទឈ្មោះ [redacted] **មិថុនា** បានឆ្លើយបដិសេធក៏ដោយ ប៉ុន្តែតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **មិថុនា** និងភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង បង្ហាញឱ្យឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់របស់តំណាងអយ្យការប្រាកដមែន ។ តំណាងអយ្យការសម្រេចរក្សាបទចោទប្រកាន់ដដែល និងសុំតុលាការសម្រេចផ្តន្ទាទោសតាមច្បាប់ ។ ដោយឡែកជនជាប់ចោទឈ្មោះ [redacted] បញ្ញា និងឈ្មោះ [redacted] **ថយ** តំណាងអយ្យការស្នើ



Scanned with CamScanner

សុំតុលាការពិចារណាតាមច្បាប់ ។

**សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ:**

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **អ៊ាវ** បានធ្វើសេចក្ដីសន្និដ្ឋាន: ក្រោយពីការពិភាក្សាដេញដោលក្នុងសវនាការ ,ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទរួចមក ឃើញថា ពាក់ព័ន្ធនឹងអង្គហេតុខាងលើ កូនក្ដីខ្ញុំបាទពុំបានប្រព្រឹត្តនោះទេ ។ ចំណែកជនជាប់ចោទឈ្មោះ [redacted] **មិថុនា** គឺឆ្លើយមកមានភាពមិនច្បាស់លាស់ ដែលនាំឱ្យដាក់បន្ទុកលើកូនក្ដីរបស់ខ្ញុំបាទ ។ ដោយឡែកជនជាប់ចោទឈ្មោះ [redacted] **ថយ** និងឈ្មោះ [redacted] **បញ្ញា** គឺឆ្លើយដោះបន្ទុកយករួចខ្លួនតែប៉ុណ្ណោះ ។ នៅថ្ងៃសមត្ថកិច្ចឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] **ថយ** ,ឈ្មោះ [redacted] **បញ្ញា** និងឈ្មោះ [redacted] **មិថុនា** គឺកូនក្ដីខ្ញុំមិនបានរត់គេចនោះទេ ។ ស្នើសុំតុលាការសម្រេចឱ្យកូនក្ដីខ្ញុំរួចផុតបទចោទ ។

លោក **ចល់ ច័ន្ទតារា** ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **បញ្ញា** ,ឈ្មោះ [redacted] **មិថុនា** ,ឈ្មោះ [redacted] **ថយ** និងឈ្មោះ [redacted] **អ៊ាវ** ហៅ **អៀវ** បានធ្វើសេចក្ដីសន្និដ្ឋាន: ក្រោយពីការពិភាក្សាដេញដោលក្នុងសវនាការ ,ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទរួចមក ឃើញថាកូនក្ដីខ្ញុំបាទឈ្មោះ [redacted] **ថយ** និងឈ្មោះ [redacted] **បញ្ញា** ពុំបានប្រព្រឹត្តបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀននោះទេ ពោលគឺបានប្រព្រឹត្តបទល្មើសប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន ។ ស្នើសុំតុលាការផ្ដន្ទាទោសពីបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។ ចំណែកកូនក្ដីខ្ញុំបាទឈ្មោះ [redacted] **មិថុនា** ពិតជាប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន ស្នើសុំតុលាការផ្ដល់ស្ថានសម្រាលទោស និងជនជាប់ចោទឈ្មោះ [redacted] **អ៊ាវ** ហៅ **អៀវ** ស្នើសុំតុលាការផ្ដន្ទាទោសតាមច្បាប់ ។

សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] **មិថុនា** បានសំណូមពរថា សូមតុលាការជួយបន្ធូរបន្ថយទោសដល់ខ្ញុំផង ព្រោះខ្ញុំដឹងកំហុសហើយ ។

សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] **ថយ** បានសំណូមពរថា សូមតុលាការជួយរកយុត្តិធម៌ដល់ខ្ញុំផង។

សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] **បញ្ញា** បានសំណូមពរថា សូមតុលាការជួយរកយុត្តិធម៌ដល់ខ្ញុំផង ។

សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] **អ៊ាវ** ហៅ **អៀវ** បានសំណូមពរថា សូមតុលាការជួយរកយុត្តិធម៌ដល់ខ្ញុំផង ព្រោះខ្ញុំមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ។

ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ក្រោយពីបានស្ដាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាងនានា

ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សំអាងហេតុ</u>

១.កាលពីថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៣ ស្ថិតនៅភូមិអង្គត្រាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ ពុំមានករណី **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ដែលប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] **ថយ** និង



Scanned with CamScanner

ឈ្មោះ [redacted] បញ្ញា នោះទេ ។

២.កាលពីថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៣ ស្ថិតនៅភូមិអង្គត្រាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ ពិតជាមានករណី **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ដែលប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] ជ័យ និងឈ្មោះ [redacted] បញ្ញា ប្រាកដមែន ។

៣.កាលពីថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៣ ស្ថិតនៅភូមិអង្គត្រាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ ពិតជាមានករណី **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ដែលប្រព្រឹត្តឡើងដោយជនជាប់ចោទ ឈ្មោះ [redacted] មិថុនា ប្រាកដមែន ។

៤.កាលពីថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៣ ស្ថិតនៅភូមិអង្គត្រាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ ពិតជាមានករណី **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ដែលប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] **អ៊ាវ ហៅ អៀវ** ប្រាកដមែន ។

៥.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] មិថុនា បានឆ្លើយថា: នៅថ្ងៃកើតហេតុ ឈ្មោះ [redacted] **អ៊ាវ** ខល ហៅខ្លួនយកថ្នាំញៀនឱ្យគេ នៅវត្តនាគត្រាច ។ ប៉ុន្តែត្រូវសមត្ថកិច្ចឃាត់ខ្លួននៅតាមផ្លូវ ។ កន្លងមក ខ្លួនធ្លាប់យកថ្នាំញៀនឱ្យឈ្មោះ **អ៊ាវ** ចំនួន ០១ លើក ហើយខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀនជាមួយគាត់ ចំនួន ០១ ដង ។ ខ្លួនស្គាល់ឈ្មោះ **អ៊ាវ** តាមរយៈឈ្មោះ **ទីន** ។ បើខ្លួនជួយយកថ្នាំញៀន គាត់ឱ្យលុយចាយខ្លះ ។ ពេលសមត្ថកិច្ចឃាត់ខ្លួន បានតេស្តទឹកនោម និងដកហូតថ្នាំញៀននៅជិតវត្ត ។ នៅថ្ងៃសមត្ថកិច្ចឃាត់ខ្លួនបានចូលឆែកឆេរផ្ទះរបស់ឈ្មោះ **អ៊ាវ** ប៉ុន្តែមិនមានថ្នាំញៀននោះទេ ។ ឈ្មោះ **អ៊ាវ** ដែលប្រើខ្លួនឱ្យយកថ្នាំញៀនឱ្យគេ គឺជាឈ្មោះ [redacted] **អ៊ាវ** ដែលនៅចំពោះមុខខ្លួននេះហើយ ។ ចំពោះថ្នាំញៀនដែលសមត្ថកិច្ចដកហូត ខ្លួនយកពីផ្ទះឈ្មោះ **អ៊ាវ** តម្លៃ ១ លាន ៨០ ម៉ឺនរៀល ។ ពេលសមត្ថកិច្ចឃាត់ខ្លួន បានតេស្តទឹកនោម ។ តាមចម្លើយសារភាពរបស់ជនជាប់ចោទនេះ អាចឱ្យតុលាការជឿជាក់បានថា ជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រាកដមែន ។

៦.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **អ៊ាវ ហៅ អៀវ** បានឆ្លើយថា: នៅថ្ងៃកើតហេតុ ខ្លួននៅត្រពាំងធំទៅធ្វើការងារ ។ ឈ្មោះ [redacted] ជ័យ ,ឈ្មោះ [redacted] មិថុនា ,ឈ្មោះ [redacted] បញ្ញា គឺស្នាក់នៅផ្ទះរបស់ខ្លួន ។ ខ្លួនស្នាក់នៅផ្ទះរបស់ខ្លួនរហូតមិនបានចេញទៅណានោះទេ ទើបតែនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៤ សមត្ថកិច្ចឃាត់ខ្លួន ។ ចំពោះថ្នាំញៀនដែលសមត្ថកិច្ចដកហូត ខ្ញុំមិនដឹងថា ជារបស់អ្នកណានោះទេ ។ បន្ទាប់ពីសមត្ថកិច្ចឃាត់ខ្លួនឈ្មោះ [redacted] មិថុនា , ឈ្មោះ [redacted] បញ្ញា និងឈ្មោះ [redacted] ជ័យ ពេលល្ងាចទើបខ្ញុំត្រឡប់មកផ្ទះវិញ ។ ខ្លួនមិនបានរត់គេចពីសមត្ថកិច្ចនោះទេ ពីព្រោះខ្លួនមិនជាប់ពាក់ព័ន្ធឡើយ ។ នៅថ្ងៃសមត្ថកិច្ចឃាត់ខ្លួន ខ្លួនមិនដឹងថាដកហូតបានអ្វីខ្លះនោះទេ ។ ខ្លួនសូមបដិសេធ ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ។ ការឆ្លើយបដិសេធរបស់ជនជាប់ចោទនេះ គឺគ្រាន់តែជាលេសដោះសារ ដើម្បីរួចផុតពីបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀនតែប៉ុណ្ណោះ ព្រោះបើពិនិត្យតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] មិថុនា និងភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿងមានភាពស៊ីសង្វាក់គ្នាបង្ហាញឱ្យតុលាការជឿជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] **អ៊ាវ ហៅ អៀវ** ពិតបានប្រព្រឹត្តបទល្មើសដូចការចោទរបស់តំណាងអយ្យការប្រាកដមែន ។



Scanned with CamScanner

៧.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ថយ បានឆ្លើយថា: កន្លងមក ខ្លួនទិញថ្នាំញៀនពីឈ្មោះ បញ្ញា ។ ខ្លួនមិនធ្លាប់ទិញថ្នាំញៀនពីឈ្មោះ [redacted] ថយ នោះទេ ។ ខ្លួនមិនបានទិញថ្នាំញៀនពីឈ្មោះ អ៊ាវ នោះទេ ។ កន្លងមកឈ្មោះ មិថុនា មិនធ្លាប់ប្រើខ្លួនឱ្យយកថ្នាំញៀនឱ្យគេនោះទេ ហើយខ្លួនក៏មិនដឹងថា ឈ្មោះ មិថុនា យកថ្នាំញៀនឱ្យអ្នកណាខ្លះ នោះដែរ ។ ខ្លួនស្គាល់ឈ្មោះ [redacted] អ៊ាវ តាមរយៈទៅធ្វើផ្ទះឱ្យគាត់ ។ ខ្លួនមិនដឹងថា ឈ្មោះ [redacted] អ៊ាវ ជាអ្នកលក់ថ្នាំញៀន ឬអត់នោះទេ ហើយខ្លួនក៏មិនធ្លាប់ប្រើប្រាស់ថ្នាំញៀនជាមួយគាត់ដែរ ។ តាមចម្លើយរបស់ជនជាប់ចោទនេះ បង្ហាញឱ្យតុលាការជឿជាក់បានថា ជនជាប់ចោទពិតបានប្រព្រឹត្តអំពើ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រាកដមែន។ ម្យ៉ាងវិញទៀតតាមចម្លើយនេះផងដែរ បង្ហាញឱ្យឃើញថាជនជាប់ចោទពុំបានប្រព្រឹត្តអំពើ**ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** នោះទេ ។

៨.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] បញ្ញា បានឆ្លើយថា: នៅថ្ងៃសមត្ថកិច្ចឃាត់ខ្លួន ខ្លួនកំពុងចាក់សាបនៅផ្ទះរបស់ឈ្មោះ អ៊ាវ ។ ខ្លួនមិនបានទិញថ្នាំញៀនពីឈ្មោះ [redacted] អ៊ាវ ហើយក៏មិនដឹងថា គាត់លក់ថ្នាំញៀន ឬអត់នោះទេ ។ ខ្លួនស្គាល់ឈ្មោះ [redacted] ថយ ,ឈ្មោះ [redacted] មិថុនា ,ឈ្មោះ [redacted] អ៊ាវ ។ តាមចម្លើយរបស់ជនជាប់ចោទនេះ បង្ហាញឱ្យតុលាការជឿជាក់បានថា ជនជាប់ចោទពិតបានប្រព្រឹត្តអំពើ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រាកដមែន ។ ម្យ៉ាងវិញទៀតតាមចម្លើយនេះផងដែរ បង្ហាញឱ្យឃើញថា ជនជាប់ចោទពុំបានប្រព្រឹត្តអំពើជួញដូរដោយខុសច្បាប់នូវសារធាតុនោះទេ ។

៩.ជនជាប់ចោទជានីតិជន និងជាសមត្ថជន ដែលមានស្មារតីយល់ដឹងពីផលវិបាកដែលកើតចេញពីអំពើប្រព្រឹត្តរបស់ខ្លួន ។

១០.អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ថយ និងឈ្មោះ [redacted] បញ្ញា បញ្ជាក់យ៉ាងច្បាស់ពីចេតនាទុច្ចរិតក្នុងការប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន គឺជាអំពើល្មើស ដែលច្បាប់តម្រូវឱ្យធ្វើការផ្តន្ទាទោស ។

១១.អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] មិថុនា បញ្ជាក់យ៉ាងច្បាស់ពីចេតនាទុច្ចរិតក្នុងការជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន គឺជាអំពើល្មើស ដែលច្បាប់តម្រូវឱ្យធ្វើការផ្តន្ទាទោស ។

១២.អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] អ៊ាវ ហៅ អៀវ បញ្ជាក់យ៉ាងច្បាស់ពីចេតនាទុច្ចរិតក្នុងការជួញដូរដោយខុសច្បាប់នូវសារធាតុញៀន គឺជាអំពើល្មើស ដែលច្បាប់តម្រូវឱ្យធ្វើការផ្តន្ទាទោស ។

១៣.អំពើប្រព្រឹត្តរបស់ជនជាប់ចោទ បានធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម ។

១៤.តាមកំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀនលេខ ៧៣/១៨ ក.ណ.ហ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ ២០២៣ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តតាកែវ តាមកំណត់ហេតុជាលទ្ធផលមានសញ្ញាវិជ្ជមាន បង្ហាញឱ្យឃើញថា ជនជាប់ចោទ ឈ្មោះ [redacted] ថយ ពិតជាបានប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន ។

១៥.តាមកំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀនលេខ ៧៣/១៨ ក.ណ.ហ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៣ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តតាកែវ តាមកំណត់ហេតុជាលទ្ធផលមានសញ្ញាវិជ្ជមាន បង្ហាញឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] បញ្ញា ពិតជាបានប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន



Scanned with CamScanner

ប្រាកដមែន ។

១៦.តាមកំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀនលេខ ៧៣/១៨ ក.ណ.ហ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៣ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តតាកែវ តាមកំណត់ហេតុជាលទ្ធផលមានសញ្ញាវិជ្ជមាន បង្ហាញឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] មិថុនា ពិតជាបានប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន ។

១៧.តាមកំណត់ហេតុធ្វើតេស្តជំហានដំបូងលេខ ៧៣/២០ ក.ណ.ហ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៣ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តតាកែវ បានបង្ហាញថាម្សៅក្រាមសថ្លាមានចំនួន ០៣ កញ្ចប់ ដែលមានសរុបទម្ងន់ ២៥,៧៦ (ម្ភៃប្រាំក្បៀសចិតសិបប្រាំមួយ) ក្រាម ជាគ្រឿងញៀនប្រភេទមេតំហ្វេតាមីន (ICE) ដែលថ្នាំញៀនជារបស់ជនជាប់ចោទឈ្មោះ [redacted] មិថុនា ប្រាកដមែន ។

១៨.តាមកំណត់ហេតុចាប់យកវត្ថុតាង និងលទ្ធផលកោសលវិច័យលើសំណាកលេខ ៤២៦១០/២៣ ម.ព.អ.ជ ប.គ.ញ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៣ របស់អាជ្ញាធរប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាលទ្ធផលបញ្ជាក់ថាវិជ្ជមានវត្ថុមានសារធាតុញៀនឈ្មោះ **មេតំហ្វេតាមីន** (Metamfetamine) ដែលគិតជាភាគរយនៃទម្ងន់គឺ ៧៤,៥៤% ស្ថិតនៅតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។ ទម្ងន់គ្រឿងញៀនប្រភេទមេតំហ្វេតាមីនដែលចាប់បានពីជនជាប់ចោទឈ្មោះ [redacted] មិថុនា គឺ ២៥,៧៦ ក្រាម ។ ហេតុនេះភាពសុទ្ធនៃគ្រឿងញៀននេះ គឺយកទម្ងន់សរុប ២៥,៧៦ ក្រាម គុណនឹង ៧៤,៥៤ ចែកនឹង ១០០ ស្មើនឹង ១៩,២០ ក្រាម ដែលស្ថិតនៅក្នុងបទឧក្រិដ្ឋដែលត្រូវផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

១៩.តាមកំណត់ហេតុទទួលវត្ថុតាង ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣ របស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តតាកែវ វត្ថុតាងរួមមាន:

-ថ្នាំញៀនប្រភេទមេតំហ្វេតាមីន (ម៉ាទឹកកក) ចំនួន ០៣ កញ្ចប់ ទម្ងន់ ២៥,៧៦ (ម្ភៃប្រាំក្បៀសម្ភៃចិតសិបប្រាំមួយ) ក្រាម

-កាំភ្លើងកែច្នៃចំនួន ០១ ដើម

-ដាវចំនួន ០១ ដើម

**គប្បីតុលាការសម្រេចត្រូវរឹបអូស និងបំផ្លាញចោល។**

-ទូរស័ព្ទចំនួន ០១ គ្រឿង ម៉ាក វីវ៉ូ

-ម៉ូតូចំនួន ០១ គ្រឿង ម៉ាករីន័រ

**គប្បីតុលាការសម្រេចរឹបអូសជាសម្បត្តិរដ្ឋ ។**

២០.គ្មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] បញ្ញា ភេទប្រុស អាយុ ២០ឆ្នាំ និងឈ្មោះ [redacted] ថយ ភេទប្រុស អាយុ ៣៨ឆ្នាំ ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិអង្គត្រាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាម



Scanned with CamScanner

បញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀននោះទេ ។ ដូចនេះ គប្បីតុលាការសម្រេចឱ្យរួចខ្លួនពីបទចោទប្រកាន់តាមបញ្ញត្តិមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២១.មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] បញ្ញា ភេទប្រុស អាយុ ២០ឆ្នាំ និងឈ្មោះ [redacted] ថយ ភេទប្រុស អាយុ ៣៨ឆ្នាំ ពីបទ: **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិអង្គត្រាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២២.មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] មិថុនា ភេទប្រុស អាយុ ២១ឆ្នាំ ពីបទ: **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិអង្គត្រាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៥ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២៣.មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **អ៊ាវ ហៅ អៀវ** ភេទប្រុស អាយុ ៣១ឆ្នាំ ពីបទ: **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិអង្គត្រាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២៤.តាមសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការថា: ក្រោយពីការពិភាក្សាដេញដោលក្នុងសវនាការ , ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទរួចមក ឃើញថា ជនជាប់ចោទឈ្មោះ [redacted] មិថុនា បានឆ្លើយសារភាពថា បានជួញដូរ និងប្រើប្រាស់ថ្នាំញៀនដោយខុសច្បាប់ ប្រាកដមែន។ ចំណែកជនជាប់ចោទឈ្មោះ [redacted] មិថុនា បានឆ្លើយបដិសេធក៏ដោយ ប៉ុន្តែតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] មិថុនា និងភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿងបង្ហាញឱ្យឃើញថា ជនជាប់ចោទពិតជា បានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ប្រាកដមែន ។ តំណាងអយ្យការសម្រេចរក្សាបទចោទប្រកាន់ដដែល និងសុំតុលាការសម្រេចផ្តន្ទាទោសតាមច្បាប់ ។ ដោយឡែកជនជាប់ចោទឈ្មោះ [redacted] បញ្ញា និងឈ្មោះ [redacted] ថយ តំណាងអយ្យការស្នើសុំតុលាការពិចារណាតាមច្បាប់។ ការស្នើសុំនេះ មានលក្ខណៈត្រឹមត្រូវ ព្រោះមានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់ គប្បីតុលាការពិចារណា ។

២៥.សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ:

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **អ៊ាវ** បានធ្វើសេចក្តីសន្និដ្ឋាន: ក្រោយពីការពិភាក្សាដេញដោលក្នុងសវនាការ ,ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទរួចមក ឃើញថា ពាក់ព័ន្ធនឹងអង្គហេតុខាងលើ កូនក្តីខ្លួនពុំបានប្រព្រឹត្តនោះទេ ។ ចំណែកជនជាប់ចោទឈ្មោះ [redacted] មិថុនា គឺឆ្លើយមកមានភាពមិនច្បាស់លាស់ ដែលនាំឱ្យដាក់បន្ទុកលើកូនក្តីរបស់ខ្លួន ។ ដោយឡែកជនជាប់ចោទឈ្មោះ [redacted] ថយ និងឈ្មោះ [redacted] បញ្ញា គឺឆ្លើយដោះបន្ទុកយករួចខ្លួនតែប៉ុណ្ណោះ ។ នៅថ្ងៃសមត្ថកិច្ចឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ថយ ,ឈ្មោះ [redacted] បញ្ញា និងឈ្មោះ [redacted] មិថុនា គឺកូនក្តីខ្លួនមិនបានរត់គេចនោះទេ ។ ស្នើសុំតុលាការសម្រេចឱ្យកូនក្តីខ្លួនរួចផុតបទចោទ ។ ការស្នើសុំនេះ ពុំមានលក្ខណៈត្រឹមត្រូវនោះទេ គប្បីតុលាការពិចារណាតាមច្បាប់ ។



Scanned with CamScanner

លោក ចល់ ច័ន្ទតារា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] បញ្ញា ,ឈ្មោះ [redacted] មិថុនា ,ឈ្មោះ [redacted] ថយ និងឈ្មោះ [redacted] អ៊ាវ ហៅ អៀវ បានធ្វើសេចក្ដីសន្និដ្ឋាន: ក្រោយពីការពិភាក្សាដេញដោលក្នុងសវនាការ ,ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទរួចមក ឃើញថាកូនក្ដីរបស់ខ្លួនឈ្មោះ [redacted] ថយ និងឈ្មោះ [redacted] បញ្ញា ពុំបានប្រព្រឹត្តបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀននោះទេ ពោលគឺបានប្រព្រឹត្តបទល្មើសប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន ។ ស្នើសុំតុលាការផ្ដន្ទាទោសពីបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។ ចំណែកកូនក្ដីខ្លួនឈ្មោះ [redacted] មិថុនា ពិតជាប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន ស្នើសុំតុលាការផ្ដល់ស្ថានសម្រាលទោស និងជនជាប់ចោទឈ្មោះ [redacted] អ៊ាវ ហៅ អៀវ ស្នើសុំតុលាការផ្ដន្ទាទោសតាមច្បាប់ ។ ការស្នើសុំនេះ គប្បីតុលាការពិចារណា ។

## ហេតុដូច្នេះសម្រេច

១/.ឱ្យជនជាប់ចោទ:

ក.ឈ្មោះ [redacted] **បញ្ញា** ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ)

ខ.ឈ្មោះ [redacted] **ថយ** ភេទប្រុស អាយុ ៣៨ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ)

រួចខ្លួនពីបទ: **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិអង្គត្រាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

២/.ផ្ដន្ទាទោសលើជនជាប់ចោទ:

ក.ឈ្មោះ [redacted] **បញ្ញា** ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ)

ខ.ឈ្មោះ [redacted] **ថយ** ភេទប្រុស អាយុ ៣៨ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ)

ដាក់ពន្ធនាគារម្នាក់ៗកំណត់រយៈពេលចំនួន ០៦ (**ប្រាំមួយ**) **ខែ** ពីបទ: **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិអង្គត្រាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

គ.ឈ្មោះ [redacted] **មិថុនា** ភេទប្រុស អាយុ ២១ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ)

ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន ០៦ (**ប្រាំមួយ**) **ឆ្នាំ** និងពិន័យជាប្រាក់ចំនួន **១០.០០០.០០០ (ដប់លាន) រៀល** ពីបទ: **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិអង្គត្រាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៥ និងមាត្រា៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

ឃ.ឈ្មោះ [redacted] **អ៊ាវ ហៅ អៀវ** ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ)

ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន ០៦ (**ប្រាំមួយ**) **ឆ្នាំ** និងពិន័យជាប្រាក់ចំនួន **១០.០០០.០០០ (ដប់លាន) រៀល** ពីបទ: **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិអង្គត្រាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៥



Scanned with CamScanner

នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣/.វត្ថុតាងរួមមាន:

-ថ្នាំញៀនប្រភេទមេតំហ្វេតាមីន (ម៉ាទឹកកក) ចំនួន ០៣ កញ្ចប់ ទម្ងន់ ២៥,៧៦ (ម្ភៃប្រាំក្បៀសម្ភៃចិតសិបប្រាំមួយ) ក្រាម

-កាំភ្លើងកែច្នៃចំនួន ០១ ដើម

-ដាវចំនួន ០១ ដើម

**ត្រូវរឹបអូស និងបំផ្លាញចោល។**

-ទូរស័ព្ទចំនួន ០១ គ្រឿង ម៉ាក វីវ៉ូ

-ម៉ូតូចំនួន ០១ គ្រឿង ម៉ាកវីនីរ

**ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។**

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៤ ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|

ហត្ថលេខា និងត្រា: [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ១១កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ខេត្តតាកែវ, ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៤

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជីសវនាការ**

[redacted]